# ម៉ូដែលមានអត្ថប្រយោជន៍

## UTILITY MODELS



# ទិដ្ឋភាពទូទៅ

- ម៉ូដែលមានអត្ថប្រយោជន៍ ជាផ្នែកមួយនៃកម្មសិទ្ធិឧស្សាហកម្ម ដែលមានលក្ខណៈ ស្រដៀងគ្នាទៅនឹងប្រកាសនីយបត្រតក្កកម្ម
- ម៉ូដែលមានអត្ថប្រយោជន៍ ពុំសូវមានការចាប់អារម្មណ៍ជាទូទៅនោះទេ ពីព្រោះនាពេលបច្ចុប្បន្នសកម្មភាពនៃការផ្ទេរប្រឌិតថ្មីមានភាពជឿនលឿនយ៉ាងខ្លាំង (ពិសេសប្រទេសកំពុងអភិវឌ្ឍន៍)

# និយមន័យ

- ម៉ូដែលមានអត្ថប្រយោជន៍ គឺជាគក្កកម្មមួយដែលថ្មី និងអាចយកទៅអនុវត្តន៍បាននៅក្នុងឧស្សាហកម្ម និងដែលអាចជាផលិតផល ឬ ដំណើរការផលិតកម្ម ឬ ដែលអាចទាក់ទងទៅនឹងផលិតផល ឬ ដំណើរការផលិតកម្ម
- គឺជាវិញ្ញាបនបត្រដែលបានផ្តល់ ដើម្បីការពារម៉ូដែល-មានអត្ថប្រយោជន៍ (មាត្រា ៦៩)

# និយមន័យ

- អ្វីដែលធ្វើឲ្យ ម៉ូដែលមានអត្ថប្រយោជន៍ខុសពីប្រកាសនីយបត្រតក្កកម្មគឺ ត្រង់ទំនាក់ទំនង និងលក្ខខណ្ឌរបស់វា ហើយម៉ូដែលមានអត្ថប្រយោជន៍ស្រដៀងគ្នានិងប្រកាសនីយបត្រតក្កកម្ម ព្រោះវាសំដៅទៅលើលក្ខណៈបច្ចេកទេស អរូបី និងមិនអាចសំគាល់បានដោយភ្នែក

# និយមន័យ

- ម៉ូដែលមានអត្ថប្រយោជន៍ ត្រូវតែជាតក្កកម្មមួយដែលថ្មីក៏ដោយ ក៏ពាក្យថាថ្មីសម្រាប់ម៉ូដែលមានអត្ថប្រយោជន៍ខុសពីប្រកាសនីយបត្រតក្កកម្មដែរ

- ជំហាននៃការរកឃើញថ្មី ដែលមានលក្ខណៈស្មុកស្មាញសម្រាប់ប្រកាសនីយបត្រតក្កកម្ម មិនត្រូវបានយកមកអនុវត្តចំពោះម៉ូដែលមានអត្ថប្រយោជន៍ឡើយ


1912
1919-25
1970-75
1998


1946
1964
1981
1999


Steam Cooker
XJ-6K203
3
2
1
Lid
2
Bowl 1X3
Tray
Power cord



# លក្ខខណ្ឌនៃការទទួលការការពារ

- ថ្មី
- អាចអនុវត្ត



# ថ្មី

- ថាតើពាក្យថាថ្មីសម្រាប់ម៉ូដែលមានអត្ថប្រយោជន៍មានអត្ថន័យយ៉ាងណា?
- មិនថាម៉ូដែលមានអត្ថប្រយោជន៍ គំនូរឧស្សាហកម្ម ឬប្រកាសនីយបត្រតក្កកម្មនោះទេ លក្ខខណ្ឌរបស់វាគឺត្រូវតែថ្មី
- បើយើងធ្វើការពិនិត្យឲ្យបានស៊ីជម្រៅទៅ លើពាក្យថាថ្មីគឺមានលក្ខណៈខុសគ្នា ដែលវាអាស្រ័យទៅតាមប្រភេទនៃតក្កកម្មនីមួយៗ

# ថ្មី

- លក្ខណៈថ្មីសម្រាប់ម៉ូដែលមានអត្ថប្រយោជន៍ គឺតក្កកម្មមួយមានការអភិវឌ្ឍន៍ផ្នែកបច្ចេកទេសតិចតួចជាង ដែលជាជំហាននៃការបង្កើតថ្មី សម្រាប់ប្រកាសនីយបត្រតក្កកម្ម ឬអាចនិយាយបានថា វាគ្រាន់តែជាការឆ្នៃប្រឌិតដែលមានលក្ខណៈខុសពីសភាពដើម ឬ ប្តូរតួនាទីរបស់វាឲ្យមានលក្ខណៈកាន់តែប្រសើរជាងមុន ឬ ឲ្យកាន់តែទំនើបជាងមុន

# ឧទាហរណ៍ទូរស័ព្ទ iPhone របស់ក្រុមហ៊ុន Apple



# អាចអនុវត្តបានក្នុងឧស្សាហកម្ម

- អាចអនុវត្តបានក្នុងឧស្សាហកម្ម គឺពុំមានលក្ខណៈខុសគ្នាពីអ្វីដែលបានចែងសម្រាប់ប្រកាសនីយបត្រតក្កកម្មឡើយ
- ការចុះបញ្ជី មានលក្ខណៈស្រដៀងគ្នាទៅនិងការចុះបញ្ជី សម្រាប់ប្រកាសនីយបត្រតក្កកម្មផងដែរ

# សំគាល់៖

- ចំណុចមួយដែលគួរធ្វើការកត់សំគាល់ផងដែរនោះ គឺប្រសិនបើតក្កករដឹងថា តក្កកម្មរបស់ខ្លួនពុំអាចទទួលបាននូវប្រកាសនីយបត្រតក្កកម្មនោះទេ នៅមុនពេល ឬ ក្រោយពីបានទទួលការឆ្លើយតបពីមន្ត្រីកាន់កាប់បញ្ជី តក្កករ ឬ អ្នកដាក់ពាក្យសុំ អាចធ្វើការផ្លាស់ប្តូរសំណុំលិខិត ស្នើសុំប្រកាសនីយបត្រតក្កកម្មរបស់ខ្លួនទៅជាសំណុំលិខិត ស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍វិញបាន

# រយៈពេលនៃការការពារ (មាត្រា ៧៣)

- រយៈពេលនៃការការពារ សម្រាប់ម៉ូដែលមានអត្ថប្រយោជន៍ គឺមានរយៈពេលខ្លីជាង ប្រកាសនីយបត្រតក្កកម្ម
- ព្រះរាជាណាចក្រកម្ពុជាយើងវិញ សម្រាប់ម៉ូដែលមានអត្ថ-ប្រយោជន៍មានរយៈពេលនៃការការពារគឺ ៧ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជី ស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍នោះ
- មិនអាចស្នើសុំឲ្យមានការការពារជាថ្មីឡើងវិញបានទេ

# មូលហេតុ?

- ដោយសារតែវិស័យ បច្ចេកវិទ្យាមានការរីកចម្រើនយ៉ាងឆាប់រហ័ស ហើយការរកឃើញនូវតក្កកម្មថ្មី ក៏មានភាពឆាប់រហ័សផងដែរ។ ជួនកាលម៉ូដែលមានអត្ថប្រយោជន៍មួយមិនទាន់ទាំងផុតរយៈពេលនៃការការពារផង ក៏ត្រូវបាត់បង់អស់នូវតម្លៃ ដោយវាត្រូវបានជំនួសមកវិញនូវតក្កកម្មថ្មីមួយទៀត ដែលជាហេតុនាំឲ្យអ្នកប្រើប្រាស់លែងត្រូវការនូវតក្កកម្មដែលមានពីមុន

# សិទ្ធិដែលទទួលបាន

- ជាទូទៅសិទ្ធិរបស់តក្កករពុំមានអ្វីខុសប្លែក ពីសិទ្ធិដែលទទួលបានពីប្រកាសនីយបត្រ តក្កកម្មនោះដែរ។ ប៉ុន្តែចំណុចសំខាន់មួយ ដែលធ្វើឲ្យម៉ូដែលមានអត្ថប្រយោជន៍ខុសពីប្រកាសនីយបត្រតក្កកម្ម គឺម្ចាស់កម្មសិទ្ធិករនៃប្រកាសនីយបត្រតក្កកម្មពុំមានសិទ្ធិ ក្នុងការប្រឆាំងទៅនឹងអំណាចសាធារណៈ (អំណាចរដ្ឋ) ក្នុងការយកតក្កកម្មរបស់ខ្លួនទៅធ្វើអាជីវកម្មទេ (ប្រយោជន៍សាធារណៈ)
- ម៉ូដែលមានអត្ថប្រយោជន៍វិញ រដ្ឋពុំមានអំណាចក្នុងការរិបអូសយកទៅធ្វើអាជីវកម្មនោះទេ

# អរគុណសម្រាប់ការយកចិត្តទុកដាក់

